# ព្រះបន្ទូលជាពន្លឺដ៏ពិតប្រាកដតែមួយ ដែលមកក្នុងពិភពលោក ហើយបំភ្លឺមនុស្សគ្រប់ៗរូប យ៉ូហាន ១,៩

## The Word is the real light that gives light to everyone Jonh 1,9



**2021**

**លោកអភិបាល អូលីវីយេ**

**Bishop Olivier**

ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ

# ព្រះយេស៊ូប្រសូត ២០២០

# ព្រះបន្ទូលជាប្រភពនៃជីវិត

## អត្ថបទទី១៖ យ៉ូហានទី១ ២,១២-១៧

*បើគេជាគ្នាយើងមែន គេមុខជានៅជាមួយយើងរហូតមិនខាន។* ១យហ ២,១៩

## ដំណឹងល្អ៖ យ៉ូហាន ១,១-១៨

*ព្រះបន្ទូលជាប្រភពនៃជីវិត ហើយជីវិតនោះជាពន្លឺបំភ្លឺមនុស្សលោក។* យហ ១,៤

បងប្អូនជាទីស្រឡាញ់!

អាលេលូយ៉ាដែលយើងបានស្ដាប់យប់នេះ បីដូចជាមានអត្ថន័យនិងបរិយាកាសផ្សេងពីយប់ដ៏សុខសាន្ត ដែលយើងបានប្រារព្ធបុណ្យព្រះយេស៊ូប្រសូតសប្ដាហ៍មុន ។ អាទិត្យមុនយើងកំពុងភ័យខ្លាចព្រឹត្តិការណ៍សហគមន៍២៨វិច្ឆិកា អំពីជំងឺកូវីដ-១៩ដែលបានឆ្លងចូលក្នុងសហគមន៍ ដែលណែនាំឲ្យយើងកាត់បន្ថយយ៉ាងច្រើន កាត់បន្ថយការជួបជុំគ្នាអបអរសាទរបុណ្យព្រះយេស៊ូប្រសូត ។ ពីរថ្ងៃកន្លងមក រាជរដ្ឋាភិបាលបានប្រកាសបញ្ចប់ព្រឹត្តិការណ៍សហគមន៍២៨វិច្ឆិកា ដោយបានអនុញ្ញាតឲ្យបើកសាលា បើកកន្លែងសិល្បៈ បើកកន្លែងហាត់កីឡាវិញ និងអនុញ្ញាតឲ្យមានការជួបជុំគ្នា ប៉ុន្តែដោយយកចិត្តទុកដាក់ថែរក្សាតាមការណែនាំរបស់ក្រសួងសុខាភិបាល ។ យប់នេះយើងសប្បាយចិត្តដែរ យើងមានអារម្មណ៍ថាយើងធូរស្រាល យើងបានបញ្ចប់ឆ្នាំ២០២០ដោយមានកម្លាំងមួយ ដែលយល់ថាប្រហែលឆ្នាំ២០២១យើងអាចទទួលព្រះពរយ៉ាងច្រើនពីព្រះជាម្ចាស់ថែមទៀត ។

នៅពេលយើងនឹកដល់ឆ្នាំ២០២០ យើងនឹកឃើញភ្លាមថាជាឆ្នាំកូវីដ-១៩ ទោះបីអ្នកដែលបានជាប់មធ្យមសិក្សាទុតិយភូមិ (បាក់ឌុប) គេបានហៅដាក់ឈ្មោះថាបាក់

ឧបកូវីដ-១៩ ដែលអស់មួយជីវិតយើងមិនអាចភ្លេចបានទេ ។ ឆ្នាំ២០២០ ពិតមែនដូច ជាបានប៉ះពាល់នៅក្នុងចិត្ត ក្នុងអារម្មណ៍ នៅក្នុងជីវិត នៅក្នុងសង្គម នៅក្នុងពិភពលោក នៅក្នុងសេដ្ឋកិច្ច នៅក្នុងគ្រប់ទំនាក់ទំនងដែលយើងមាន ដោយសារមេរោគ កូវីដ-១៩ ដែលកើតឡើងនៅខែធ្នូ ឆ្នាំ២០១៩ នៅប្រទេសចិន ។ យើងត្រូវតែអរព្រះគុណព្រះជាម្ចាស់ ដោយសារព្រះអង្គបានថែរក្សាការពារយើងនៅប្រទេសកម្ពុជា ព្រោះយើងមានអ្នកឆ្លងជំងឺកូវីដ-១៩នេះតិចណាស់ ។ នៅពេលយើងបានឃើញក្នុងពិភពលោកមានអ្នកស្លាប់រាប់លាននាក់ និងបានប៉ះពាល់ដល់មនុស្សរាប់លាននាក់ យើងត្រូវតែអរព្រះគុណព្រះជាម្ចាស់ដែលបានថែរក្សាប្រទេសយើង ។ ប៉ុន្តែ សព្វថ្ងៃយើងមិនអាចរស់នៅជាសង្គមមួយឯករាជ្យម្នាក់ឯង ដែលឥតមានទំនាក់ទំនងជាមួយសង្គមដទៃបានទេ យើងជាប្រទេសមួយដែលចូលនៅក្នុងសហគមន៍អាស៊ាន ដែលចូលនៅក្នុងទ្វីបអាស៊ី ដែលចូលនៅក្នុងពិភពលោកទាំងមូល ។ គ្រប់បញ្ហាដែលកើតឡើងនៅទ្វីបអឺរ៉ុប នៅទ្វីបអាមេរិក ឬនៅក្នុងប្រទេសជិតខាងយើងក៏មានឥទ្ធិពលលើជីវិតរបស់យើងដែរ ។ ទោះបីយើងមានអ្នកជំងឺតិចក៏ដោយ ទោះបីយើងគ្មានអ្នកណាស្លាប់ក៏ដោយ ប៉ុន្តែយើងដឹងថាសេដ្ឋកិច្ចប្រទេសយើងធ្លាក់ភាគរយខ្លះ និងសេដ្ឋកិច្ចគ្រួសារមួយចំនួនពិបាកមែនទែន ។

ដូច្នេះ ឆ្នាំ២០២០ដូចជាបានណែនាំឲ្យយើងទុកអនុស្សាវរីយ៍មិនសូវល្អប៉ុន្មានទេ ប៉ុន្តែយើងជាគ្រីស្តបរិស័ទយើងត្រូវការបើកភ្នែកមើលអំពីអ្វីដែលល្អ អំពីអ្វីដែលបានណែនាំឲ្យយើងឃើញវត្តមានរបស់ព្រះជាម្ចាស់ ។ កុំឲ្យយើងភ្លេច ទោះបីនៅក្នុងទុក្ខលំបាកក៏ដោយ ទោះបីនៅក្នុងអំណរសប្បាយក៏ដោយ យើងដឹងថាវត្តមានរបស់ព្រះជាម្ចាស់គង់នៅជានិច្ច ។ ដូច្នេះ ឥតមានទុក្ខលំបាកណាមួយដែលយើងបានជួបនៅក្នុងជីវិតរបស់យើងផ្ទាល់ ក៏ដូចជានៅក្នុងសង្គមដែលដឹងថាព្រះជាម្ចាស់មិនគង់នៅនោះទេ ។ ដូចយើងបានស្ដាប់ថា **"ព្រះបន្ទូលជាប្រភពនៃជីវិត ហើយជីវិតនោះជាពន្លឺបំភ្លឺមនុស្សលោក"** ព្រះបន្ទូលនៅក្នុងជីវិតរបស់យើង ។ ពីថ្ងៃដែលព្រះយេស៊ូប្រសូត មានន័យថាព្រះបន្ទូលបានចាប់កំណើតជាមនុស្ស ដើម្បីធ្វើដំណើរជាមួយយើង ។ ព្រះបន្ទូលដែលជាពន្លឺ ចាប់កំណើតនៅក្នុងជីវិតរបស់យើងដែលមានទុក្ខលំបាក ដែលមានអំណរសប្បាយ ដែលមានភាពងងឹតដើម្បីរកឃើញពន្លឺ ។ ខ្ញុំគិតថាមួយឆ្នាំកន្លងមកដោយសារជំងឺកូវីដ-១៩ យើងបានយកចិត្តទុកដាក់យ៉ាងច្រើន ប្រសិនបើយើងមើលការបន្តការសិក្សានៅក្នុងសាលា

កាតូលិកទូទាំងភូមិភាគភ្នំពេញ ។ មើលរបៀបដែលយើងបានយកចិត្តទុកដាក់បន្តមាន អធិដ្ឋាន មានអភិបូជាតាមរយៈការផ្សាយបន្តផ្ទាល់ (Live) ដែលការិយាល័យផ្សព្វផ្សាយ ព័ត៌មានកាតូលិកយើងបានយកចិត្តទុកដាក់មែនទែន ដើម្បីឲ្យគ្រីស្តបរិស័ទមានឱកាស ស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ពីមួយថ្ងៃទៅមួយថ្ងៃ ។ មើលរបៀបដែលការិយាល័យ យុវជន បានបន្តសកម្មភាពនានាជាមួយយុវជន ជាមួយកាយឫទ្ធិ ពេលខ្ញុំឃើញព្រះសហគមន៍ នីមួយៗនៅក្នុងភូមិភាគភ្នំពេញ ជិតមួយឆ្នាំកន្លងមកបានខិតខំរកមធ្យោបាយថ្មី របៀប ថ្មី កែច្នៃប្រឌិតដើម្បីមានសកម្មភាព ។ សកម្មភាពមេត្តាករុណា សកម្មភាពជាមួយកូន ក្មេងនិងយុវជន សកម្មភាពអធិដ្ឋាន ដោយគោរពតាមការណែនាំរបស់រដ្ឋាភិបាល ។

ព្រះសហគមន៍របស់យើងបានបន្តមានជីវិត ពិតមែនព្រះបន្ទូលជាប្រភពនៃជីវិត និង ព្រះបន្ទូលដែលបានចាប់កំណើតជាមនុស្ស យើងដឹងថាមានវត្តមានរបស់ព្រះជាម្ចាស់ ដែល ណែនាំឲ្យអាចបន្តជីវិត ។ ជីវិតត្រូវតែបន្ត ដោយសារព្រះយេស៊ូប្រសូត ដោយសារ ទេវទូតបានប្រាប់ព័ត៌មានដល់ព្រះនាងម៉ារីហើយព្រះនាងបានឯកភាពធ្វើជាមាតារបស់ ព្រះជាម្ចាស់ ។ ដូច្នេះ សេចក្តីសង្ឃឹមដែលយើងទទួលនៅក្នុងរាត្រីព្រះយេស៊ូប្រសូត បាន ណែនាំឲ្យយើងអាចមើលឃើញឆ្នាំ២០២០សាជាថ្មី ។ យើងអរព្រះគុណព្រះជាម្ចាស់ ដែល បានគង់នៅជាមួយយើងដើម្បីឲ្យយើងបន្តប្រកាសដំណឹងល្អ បន្តរស់នៅជាគ្រីស្តបរិស័ទ បន្តរស់នៅជាជីវិតពលរដ្ឋធម្មតានៅក្នុងសង្គម បន្តតស៊ូនៅក្នុងជីវិត ទោះបីមានទុក្ខលំបាក ក៏ដោយ យើងត្រូវតែអរព្រះគុណព្រះជាម្ចាស់សម្រាប់ឆ្នាំ២០២០ដែរ ។

ឆ្នាំ២០២១ អ្វីដែលនឹងកើតឡើងយើងមិនដឹងហើយយើងមិនហ៊ាននិយាយ ដោយសារ កន្លងមកពេលក្រសួងអប់រំសម្រេចចិត្តបើកសាលាវិញ មួយសប្តាហ៍ក្រោយមកបិទ វិញ... ។ ដូច្នេះធ្វើគម្រោងការមិនស្រួលប៉ុន្មានទេ ក៏ប៉ុន្តែយើងអាចជូនពរគ្នាទៅវិញ ទៅមក ជាពិសេសខ្ញុំក្នុងនាមជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ខ្ញុំសូម ឆ្លៀតឱកាស ដើម្បីជូនពរដល់បងប្អូនទាំងអស់នៅក្នុងមណ្ឌលសកម្មភាពនីមួយៗ នៅតាម កន្លែងនីមួយៗដែលព្រះសហគមន៍យើងមានវត្តមានគឺ៖

**ទីមួយ** សូមឲ្យព្រះជាម្ចាស់គង់នៅ សម្រាប់យើងដែលចូលនៅក្នុងអភិបូជាយប់នេះ ជាអ្វីដែលយើងសង្ឃឹម ឲ្យឆ្នាំ២០២១យើងចម្រើនពរ ។ ឲ្យពរីកចម្រើននៅក្នុងជីវិត

របស់យើង ឲ្យព្រះពរដែលយើងបានទទួលពីព្រះជាម្ចាស់រីកចម្រើន និងស្ថិតស្ថេរនៅក្នុងជីវិតរបស់យើង ឲ្យយើងមានសេចក្ដីសុខនៅក្នុងដួងចិត្តរបស់យើង ។ ឲ្យព្រះពររបស់ព្រះជាម្ចាស់ចម្រើនយ៉ាងខ្លាំងណាស់ នៅក្នុងគ្រួសារនីមួយៗ នៅក្នុងព្រះសហគមន៍នីមួយៗ នៅក្នុងជីវិតរបស់យើងផ្ទាល់ និងនៅក្នុងប្រទេសកម្ពុជាទាំងមូល ។

**ទីពីរ** ព្រះបន្ទូលជាប្រភពនៃជីវិត ខ្ញុំសូមអញ្ជើញបងប្អូនយកចិត្តទុកដាក់ស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីដឹកនាំជីវិតរបស់យើង ។ នៅក្នុងរដូវរង់ចាំកន្លងមកជារៀងរាល់អាទិត្យយើងបានស្ដាប់ព្រះបន្ទូល យើងបានរិះគិតពិចារណា តើព្រះបន្ទូលនេះបំភ្លឺជីវិតរបស់ខ្ញុំដូចម្ដេច? តើព្រះបន្ទូលនេះណែនាំឲ្យខ្ញុំទៅមុខដូចម្ដេច? ប្រសិនបើព្រះនាងម៉ារីមិនបានទទួលព្រះបន្ទូលរបស់ព្រះជាម្ចាស់ ប្រសិនបើលោកយ៉ូសែបមិនបានទទួលព្រះបន្ទូលរបស់ព្រះជាម្ចាស់ តើព្រះយេស៊ូអាចចាប់កំណើតជាមនុស្សបានទេ? ដូច្នេះសម្រាប់យើងក៏ដូចគ្នាដែរនៅក្នុងការពិបាក នៅក្នុងអំណរ នៅក្នុងជីវិតរបស់យើងពីមួយថ្ងៃទៅមួយថ្ងៃ ឲ្យយើងយកចិត្តទុកដាក់ស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីដឹកនាំជីវិតយើង ។

**ទីបី** ខ្ញុំបាននឹកឃើញថាក្នុងរដូវកូវីដ-១៩ ព្រះសហគមន៍របស់យើងបាត់បង់សំឡេងច្រើន យើងមានគ្នាតិចហើយឥតមានឱកាសជួបគ្នាច្រើនទៀត ។ ប៉ុន្តែ អ្វីដែលសំខាន់ទោះបីយើងគ្នាតិចក៏ដោយ ឲ្យយើងបង្ហាញអំពីអត្តសញ្ញាណរបស់យើងជាគ្រីស្តបរិស័ទអំពីអត្តសញ្ញាណរបស់យើងជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ។ តាមរយៈការផ្សាយផ្ទាល់យើងបានឃើញរបៀបដែលយើងបានរៀបចំ របៀបដែលយើងបញ្ចូលសិល្បៈ យើងបានបង្ហាញអំពីអត្តសញ្ញាណរបស់យើង ដែលជាកូនខ្មែរបានទទួលជីវិតពីព្រះជាម្ចាស់ដែលកោតសរសើរព្រះជាម្ចាស់ ដែលថ្វាយបង្គំព្រះជាម្ចាស់ ។ ឲ្យយើងគិតម្ដងទៀត ខ្ញុំជាគ្រីស្តបរិស័ទនៅក្នុងប្រទេសកម្ពុជាមួយរូប តើខ្ញុំធ្វើដូចម្ដេចដើម្បីថែរក្សាអត្តសញ្ញាណរបស់ខ្ញុំជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់? ដោយនឹកឃើញធម៌វិន័យស្រឡាញ់គ្នាទៅវិញទៅមក ដោយនឹកឃើញយើងជាបងប្អូនគ្នាដោយសារយើងជាបុត្រធីតារបស់ព្រះជាម្ចាស់ ដោយនឹកឃើញយើងមានព្រះយេស៊ូដែលជាព្រះពន្លឺ ។ កុំឲ្យយើងបាត់បង់ជីវិតរបស់យើងជាគ្រីស្តបរិស័ទ ដោយសារជំងឺកូវីដ-១៩ ខ្ញុំបានឃើញផ្ទាល់ភ្នែកក្នុងភូមិភាគភ្នំពេញ

មានមនុស្សមួយចំនួន បានឆ្លៀតឱកាសដើម្បីទៅឆ្ងាយពីព្រះសហគមន៍ ដោយមិនបានមើលការផ្សាយផ្ទាល់តាមហ្វេសបុក ឬយូធូប ។ ខ្ញុំសង្ឃឹមថា ឆ្នាំ២០២១ជាពេលវេលាសម្រាប់យើងទាំងអស់គ្នាភ្ញាក់ស្មារតី ខ្ញុំជាកូនខ្មែរដែលបានទទួលពិធីជ្រមុជទឹក ឲ្យអត្តសញ្ញាណរបស់ខ្ញុំចេញជាក់ស្តែង ។

**ទីបួន** ខ្ញុំសូមជូនពរឲ្យយើងទាំងអស់គ្នាថែរក្សាជំនឿរបស់យើង នៅក្នុងគ្រប់កាលៈទេសៈ ។ កាលៈទេសៈពិបាកក៏ដោយ កាលៈទេសៈស្រួលក៏ដោយ ឲ្យយើងថែរក្សាជំនឿរបស់យើងយ៉ាងរឹងមាំ ដើម្បីឲ្យយើងអាចទៅមុខនៅក្នុងគ្រប់ដំណាក់កាលនៃជីវិតរបស់យើង ។

**ទីប្រាំ** ឲ្យយើងថែរក្សាសញ្ញាសម្គាល់នៃធម៌មេត្តាករុណានៅក្នុងជីវិតយើង យើងមានជំនឿហើយផ្លែនៃជំនឿគឺធម៌មេត្តាករុណា ។ ប្រសិនបើ យើងរកមូលហេតុលះបង់ចោលសេចក្តីស្រឡាញ់ និងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ យើងលែងភ្ជាប់ជាមួយព្រះជាម្ចាស់ ។ ដូចយើងបានស្តាប់នៅក្នុងអត្ថបទគម្ពីរ "**អ្នកណាភ្ជាប់ជាមួយព្រះជាម្ចាស់ អ្នកនោះពោរពេញដោយសេចក្តីស្រឡាញ់**" ។ ឲ្យយើងយកចិត្តទុកដាក់ដើម្បីទៅជាសញ្ញានៃធម៌មេត្តាករុណាជានិច្ច រួមជាមួយព្រះជាម្ចាស់ ។ យើងមានគំរូដើម្បីទៅមុខ គឺសន្តយ៉ូសែប សម្តេចប៉ាបបានណែនាំឲ្យឆ្នាំនេះយើងមើលសន្តយ៉ូសែបដែលជាឪពុក សន្តយ៉ូសែបដែលជាប្តី សន្តយ៉ូសែបដែលធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ សន្តយ៉ូសែបដែលជាពលករបានយកចិត្តទុកដាក់លើការងារ សន្តយ៉ូសែបដែលជាមនុស្សមានគំនិតកែច្នៃប្រឹងប្រែងជានិច្ចដើម្បីថែរក្សាគ្រួសារឲ្យរស់នៅក្នុងសេចក្តីសុខ និងសន្តយ៉ូសែបដែលលាក់ខ្លួនដើម្បីឲ្យយើងមើលឃើញព្រះយេស៊ូ ។ ពេលយើងសំឡឹងមើលរោងព្រះយេស៊ូប្រសូតតាមកន្លែងនីមួយៗ ពិតមែនយើងមើលលោកយ៉ូសែប ពិតមែនយើងមើលព្រះនាងម៉ារីប៉ុន្តែលោកទាំងពីរកំពុងមើលព្រះយេស៊ូ ។ របៀបដែលលោកយ៉ូសែបនិងព្រះនាងម៉ារីកំពុងសំឡឹងមើលព្រះយេស៊ូ ណែនាំឲ្យយើងសំឡឹងមើលព្រះយេស៊ូដែរ ។

ខ្ញុំសូមទូលអង្វរព្រះជាម្ចាស់ សូមព្រះអង្គប្រទានសេចក្តីសុខសាន្ត ប្រទានសុខភាពល្អ ប្រទានសេចក្តីក្លាហាន ចិត្តតស៊ូ សម្រាប់ព្រះសហគមន៍របស់យើងទាំងអស់ ជាពិសេសសម្រាប់មណ្ឌលសកម្មភាពនីមួយៗដែលយើងមាននៅក្នុងភូមិភាគភ្នំពេញ ។ មណ្ឌលសកម្មភាពភ្នំពេញថ្មី មណ្ឌលសកម្មភាពភ្នំពេញខាងជើង មណ្ឌលសកម្មភាពភ្នំពេញ

ខាងត្បូង មណ្ឌលសកម្មភាពទន្លេមេគង្គ មណ្ឌលសកម្មភាពទន្លេបាសាក់ មណ្ឌលសកម្មភាពតាខ្មៅ មណ្ឌលសកម្មភាពតាកែវ មណ្ឌលសកម្មភាពកំពត-កែប មណ្ឌលសកម្មភាពកំពង់សោម ឲ្យយើងមានកម្លាំងកាយកម្លាំងចិត្តដើម្បីទៅមុខនៅក្នុងជីវិតរបស់យើងជាគ្រីស្តបរិស័ទ ។ ខ្ញុំសូមទូលអង្វរព្រះជាម្ចាស់ សម្រាប់លោកឪពុកទាំងអស់ សម្រាប់បព្វជិតបព្វជីតាទាំងអស់ ដើម្បីឲ្យយើងបន្តធ្វើដំណើរជាមួយគ្នាដោយយកចិត្តទុកដាក់ថែរក្សាព្រះសហគមន៍ដែលយើងបានទទួល ។ ខ្ញុំសូមជូនពរនិងផ្ញើការអធិដ្ឋានសួរសុខទុក្ខដល់ការិយាល័យនីមួយៗនៅក្នុងភូមិភាគភ្នំពេញ ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក ការិយាល័យយុវជន ការិយាល័យការសិក្សាកាតូលិក ការិយាល័យសុខភាព ការិយាល័យអប់រំជំនឿនិងគម្ពីរ ការិយាល័យសហគ្រិនសង្គម ការិយាល័យសិល្បៈ ការិយាល័យរដ្ឋបាលលោកអភិបាល ការិយាល័យស្វាគមន៍ គណៈកម្មការពលករ... ។ ពេលខ្ញុំឃើញរបៀបដែលយើងបានរស់នៅក្នុងកូវីដ-១៩នេះ ខ្ញុំគិតថាជាពេលវេលាដើម្បីឲ្យការិយាល័យទាំងអស់ មានប្រជុំមួយយ៉ាងធំដើម្បីគិត តើយើងអាចឆ្លើយតបសំណួរដែលយើងបានឃើញយ៉ាងជាក់ស្តែងនៅក្នុងរដូវកូវីដ-១៩ដូចម្តេច ដើម្បីឲ្យភូមិភាគភ្នំពេញរីកចម្រើនថែមទៀត? ជាពិសេសផ្នែកការសិក្សាអប់រំ ផ្នែកសុខភាពសំខាន់ណាស់ ខ្ញុំសង្ឃឹមថាយើងអាចរីកចម្រើនថែមទៀត យ៉ាងតិចឲ្យយើងមានមណ្ឌលថែទាំសុខភាពកុំឲ្យយើងមានជំងឺពេលក្រោយ ។

ខ្ញុំបានឃើញនៅក្នុងរដូវកូវីដ-១៩ មនុស្សតូចតាចពិបាកណាស់ ដូច្នេះខ្ញុំសូមជំរុញឲ្យព្រះសហគមន៍ភូមិភាគភ្នំពេញយកចិត្តទុកដាក់ថែមទៀត ។ ជាពិសេសជាមួយជនមានពិការភាព ដើម្បីឲ្យយើងមានសកម្មភាពថ្មីៗ ដោយយើងបានដឹងថាក្រុមសហជីវិនព្រះយេស៊ូ (ជេស្វីត) បានបិទមជ្ឈមណ្ឌលនៅបន្ទាយព្រាបបិទសកម្មភាពទាំងអស់ ។ ដូច្នេះខ្ញុំសង្ឃឹមថាព្រះសហគមន៍អាចបន្តដើម្បីឲ្យជនមានពិការភាពអាចមានជីវិតតទៅទៀត និងចូលនៅក្នុងសង្គមដូចមនុស្សធម្មតា ។ ការិយាល័យនីមួយៗ ដូចលោកយ៉ូហានបាទីស្ទ **"លោកយ៉ូហានបាទីស្ទយាងមកដើម្បីទៅជាសាក្សីនៃពន្លឺ ដើម្បីធ្វើជាបន្ទាល់ផ្តល់សក្ខីភាពអំពីពន្លឺ"** ។ ខ្ញុំគិតថាមណ្ឌលសកម្មភាព និងការិយាល័យនីមួយៗនៅក្នុងភូមិភាគភ្នំពេញគឺ យើងជាពន្លឺប៉ុន្តែយើងមិនមែនជាព្រះយេស៊ូ ។ ដូច្នេះ យើងផ្តល់សក្ខីភាពអំពីពន្លឺដើម្បីណែនាំឲ្យមនុស្សទាំងអស់ តាមរយៈសកម្មភាពនៅក្នុង

ការិយាល័យនីមួយៗយើងអាចផ្តល់សក្ខីភាពរបស់ព្រះយេស៊ូដែលជាព្រះពន្លឺ ។ រួមជាមួយអង្គការកាតូលិក រួមជាមួយគ្រីស្តបរិស័ទដែលប្រកាសដំណឹងល្អ និងរួមជាមួយស្ថាប័ននានាដែលយើងមាននៅក្នុងភូមិភាគភ្នំពេញ   ខ្ញុំសូមព្រះជាម្ចាស់ប្រទានព្រះពរដល់បងប្អូនទាំងអស់ ដើម្បីឲ្យយើងរួមគ្នាយកព្រះបន្ទូលរបស់ព្រះអង្គទៅជាត្រីវិស័យនៅក្នុងឆ្នាំ២០២១ ដើម្បីឲ្យយើងធ្វើដំណើររួមជាមួយគ្នាក្រោមពន្លឺរបស់ព្រះគ្រីស្តពិតមែន ។  សូមជូនពរឲ្យឆ្នាំ២០២១  ទៅជាឆ្នាំដែលយើងពោរពេញដោយព្រះពរ  និងសេចក្តីសុខសាន្តដែលមកពីព្រះជាម្ចាស់ ។ អាម៉ែន ៕

ធម្មទេសនារបស់លោកអភិបាល អូលីវីយេ៉

ព្រះពរ និងពាក្យជូនពរឆ្នាំថ្មី២០២១ សម្រាប់ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ

ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

# បុណ្យព្រះយេស៊ូសម្តែងព្រះអង្គ ២០២១

**“ដោយសារដំណឹងល្អ មនុស្សទាំងអស់នៅលើផែនដីមានសិទ្ធិចូលរួមទទួលមត៌ក មានសិទ្ធិចូលរួមក្នុងព្រះកាយតែមួយ និងមានសិទ្ធិទទួលព្រះពរ តាមព្រះបន្ទូលសន្យា”**

បងប្អូនជាទីស្រឡាញ់!

នេះជាអត្ថន័យនៃពិធីបុណ្យព្រះជាម្ចាស់សម្តែងព្រះអង្គ ដែលយើងប្រារព្ធថ្ងៃនេះ ។ ដោយសារហោរាចារ្យដែលមកពីខាងកើត ព្រះជាម្ចាស់បានសម្តែងឲ្យមនុស្សលោកមើលឃើញព្រះបុត្រារបស់ព្រះអង្គ ។

យើងអាចនិយាយថា ព្រះជាម្ចាស់ជាមេ ជាគ្រូដ៏ពិសេសបំផុតក្នុងការផ្សព្វផ្សាយព័ត៌មាន ។

នៅក្នុងរឿងដែលយើងបានស្តាប់ពីថ្ងៃព្រះយេស៊ូប្រសូត ថ្ងៃនេះមានតែផ្កាយមួយ ហោរាចារ្យបីនាក់ មានស្តេចហេរ៉ូដ មានសុបិនដែលណែនាំឲ្យហោរាចារ្យយល់ថាត្រូវធ្វើដំណើរទៅវិញ ។

យើងនៅឆ្ងាយពីបច្ចុប្បន្ននេះដែលយើងមានទាំងអស់ យើងមានអ៊ិនធើណេត ហ្វេសបុក បន្ថែមទៀតយើងមានហ្វាយជី(5G) ដែលណែនាំឲ្យយើងចូលគ្រប់បញ្ហាដែលកើតឡើងនៅក្នុងពិភពលោកជារៀងរាល់ថ្ងៃ ។ អ្នករកស៊ីតាមយូធូប(Youtuber) ជួនកាលមានអ្នកដើរតាមរាប់លាននាក់ រាល់ថ្ងៃគេនិយាយដល់មនុស្សរាប់លាននាក់ ជាមនុស្សដែលគេមិនដែលស្គាល់សោះ ។

ផ្ទុយពីអ្វីដែលយើងបានស្តាប់នៅក្នុងគម្ពីរដំណឹងល្អ មានតែស្តេចដែលចង់សម្លាប់ មានតែម្តាយម្នាក់ ឪពុកម្នាក់ កូនង៉ែតដែលកើតថ្មីៗនាក់ នៅក្នុងភូមិងងឹតឥតល្បីសោះ ហើយដែលពួកគេកំពុងត្រៀមគេចខ្លួនទៅប្រទេសអេហ្ស៊ីប ។

ប៉ុន្តែរឿងដ៏សម្ងាត់នេះ ២000ឆ្នាំក្រោយមកយើងនៅតែនិយាយអំពីរឿងនេះដដែល ។ ទោះបីនៅក្នុងទ្វីបអាស៊ីយើង ពេលយើងចូលនៅក្នុងខែធ្នូគ្រប់ទីក្រុង បានរៀបចំដើមគ្រីស្មាស់ តុបតែងភ្លើង មានតាណូអែល មានកាដូ... ។

សម្រាប់យើងដោយសារជំងឺកូវីដ-១៩ យើងបានតឹងរឹងបំផុតតែពីថ្ងៃទី២៤ ដល់ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២0!!! **តើនេះជាសញ្ញាមួយទេ?** ជាសញ្ញាមួយដែលណែនាំឲ្យយើងជាគ្រីស្តបរិស័ទ បានឆ្លៀតឱកាសដើម្បីគោរពបុណ្យព្រះយេស៊ូប្រសូតជាលក្ខណៈគ្រួសារពិតមែន ។ យើងបានយកចិត្តទុកដាក់ ដើម្បីណែនាំឲ្យកូនក្មេងមួយចំនួនតាមថ្ងៃផ្សេងៗពីគ្នា អាចចូលរួមនៅក្នុងអំណរសប្បាយនេះ ។ យើងបានយកចិត្តទុកដាក់ ដើម្បីណែនាំឲ្យចាស់ជរានិងគ្រួសារក្រីក្រ អាចទទួលបានសេចក្តីសុខរួមជាមួយយើងនៅក្នុងថ្ងៃបុណ្យព្រះយេស៊ូប្រសូត ។

ថ្ងៃនេះ ព្រំដែននៃការជួបជុំគ្នាដូចជាធូរស្រាលជាងមុន យើងជួបជុំគ្នាត្រូវការពាក់ម៉ាស់ លាងដៃជាមួយកាល់កុលឬជែលលាងដៃ ។ យើងមានសេចក្តីសង្ឃឹម ដែលគេចាប់ផ្តើមចាក់វ៉ាក់សាំងនៅប៉ុន្មានប្រទេស យើងបានឃើញជីវិតចាប់ផ្តើមរស់ឡើងវិញសាជាថ្មី ។ ប៉ុន្តែ នៅក្នុងអំណរសប្បាយនេះ នៅក្នុងសេចក្តីសង្ឃឹមនេះ កុំឲ្យយើងភ្លេចបេសកកម្មរបស់យើងគឺប្រកាសដំណឹងល្អ ។

នៅក្នុងឱកាសចូលឆ្នាំសកល២០២១ បងប្អូនទទួលបានពាក្យជូនពររបស់ខ្ញុំប្រាំគឺ **ទីមួយ** ឲ្យយើងពោរពេញដោយព្រះពរពីព្រះជាម្ចាស់ ។ **ទីពីរ** ឲ្យឆ្នាំនេះយើងយកចិត្តទុកដាក់រស់នៅ ដោយយកព្រះបន្ទូលដំណឹងល្អដឹកនាំជីវិតរបស់យើង ។ **ទីបី** ឲ្យយើងនឹកឃើញចូលជ្រៅនៅក្នុងអត្តសញ្ញាណរបស់យើងជាគ្រីស្តបរិស័ទកាតូលិកលើទឹកដីកម្ពុជា ។ **ទីបួន** ឲ្យយើងការពារជំនឿរបស់យើងឲ្យរឹងមាំ និង**ទីប្រាំ** ឲ្យយើងចែករំលែកសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់យ៉ាងសកម្ម ។

**តើយើងធ្វើដូចម្តេច ដើម្បីទៅជាសាក្សីនៃដំណឹងល្អនេះនៅក្នុងសង្គមរបស់យើងបច្ចុប្បន្ននេះ?**

ខ្ញុំសូមអញ្ជើញបងប្អូនឲ្យអង្គុយតាមព្រះសហគមន៍នីមួយៗ តាមគណៈកម្មការនីមួយៗ តាមការិយាល័យនីមួយៗនៅក្នុងភូមិភាគភ្នំពេញ ក្រុមបូជាចារ្យ ក្រុមបព្វជិតបព្វជិតា ក្រុមអង្គការកាតូលិក ក្រុមអ្នកស្ម័គ្រចិត្តទាំងអស់ ដើម្បីនឹកឃើញយើងមើលអ្វីដែលបានកើតឡើងនៅក្នុងឆ្នាំ២០២០ដោយសារជំងឺកូវីដ-១៩ ។ យើងបានរៀនអំពីភាពខ្សោយរបស់យើង អំពីភាពរឹងមាំរបស់យើងដែរ ដូច្នេះជាពេលវេលាដើម្បីប្រមូលទាំងភាពខ្សោយរបស់យើង ទាំងភាពខ្លាំងរបស់យើង ចូលរួមដើម្បីគិតពិចារណា **តើយើងជាព្រះសហគមន៍កាតូលិកនៅក្នុងភូមិភាគភ្នំពេញ នៅក្នុងឆ្នាំ២០២១នេះនៅក្នុងបទពិសោធន៍នៃព្រំដែន និងបញ្ហានានាដែលយើងបានជួបប្លែកៗនៅក្នុងឆ្នាំ២០២០ ដោយសារកូវីដ-១៩ យើងអាចប្រកាសដំណឹងល្អនៅក្នុងរបៀបថ្មីដូចម្តេច?**

ខ្ញុំនឹងមិនឆ្លើយវាថ្ងៃនេះទេ វានឹងក្លាយជាការខិតខំរួមគ្នារបស់យើងក្នុងឆ្នាំ២០២១ ប៉ុន្តែ ខ្ញុំសូមលើកយកចំណុចតែមួយក្នុងព្រឹកថ្ងៃបុណ្យព្រះយេស៊ូសម្តែងព្រះអង្គនេះ គឺដើម្បីប្រកាសដំណឹងល្អយ៉ាងច្បាស់លាស់ យើងត្រូវការមានឯកទេសដើម្បីផ្សាយដំណឹងល្អនេះ ។ ប៉ុន្តែ **តើជាទំនាក់ទំនងមាននៅលើបណ្តាញសង្គមជាមួយមិត្តភ័ក្តរាប់ពាន់រាប់លាន់នាក់ ដែលជាមិត្តសិប្បនិម្មិតនេះឬ?**

ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានកើតជាមនុស្ស នៅយប់បុណ្យព្រះយេស៊ូប្រសូត ព្រះជាម្ចាស់មិនយាងមកនៅក្នុងពិភពលោកទូទៅ ព្រះជាម្ចាស់មិនយាងមកនៅក្នុងជីវិតរបស់មនុស្សលោកទូទៅ ព្រះជាម្ចាស់យាងមកនៅភូមិបេថ្លេហិមយ៉ាងច្បាស់លាស់ និងព្រះជាម្ចាស់យាងមកនៅក្នុងព្រះយេស៊ូ ដែលមានម្តាយឈ្មោះម៉ារី ដែលមានឪពុកឈ្មោះយ៉ូសែប ក្នុងគ្រួសារដ៏តូចមួយ ។

**ព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលបានចាប់កំណើតជាមនុស្ស ហើយបន្តចាប់កំណើតជាមនុស្សនៅក្នុងសតវត្សទី២១នេះឬទេ?**

យើងត្រូវការភ្ជាប់គ្នា ទាំងទំនាក់ទំនងនៅក្នុងសង្គម ទាំងផ្លូវវិញ្ញាណយ៉ាងជាក់ស្តែង ។

ខ្ញុំឃើញពេលខ្ញុំបានផ្ញើតាមវ៉ាត់ស្អេប (WhatsApp) អ្វីដែលបងប្អូនបានចាប់អារម្មណ៍ច្រើនជាងគេ គឺនៅពេលខ្ញុំបានផ្ញើព័ត៌មានប្រាប់ថា ថ្ងៃនេះខ្ញុំបានថ្វាយអភិបូជាពិសេសសម្រាប់បងប្អូន ថ្ងៃនេះខ្ញុំបានជិះកង់ពីតាកែវមកភ្នំពេញ ដោយអធិដ្ឋានសម្រាប់បងប្អូន និងអង្វរព្រះជាម្ចាស់ឲ្យប្រទានព្រះពរដល់បងប្អូន ថ្ងៃនេះខ្ញុំបានអធិដ្ឋានផ្ទាល់សម្រាប់បងប្អូន ។ ត្រូវការបង្ហាញអំពីភាពជិតស្និទ្ធនៅតាមផ្លូវវិញ្ញាណ ។

ដោយសារជំងឺកូវីដ-១៩ មុនដំបូងយើងនិយាយអំពី (Social Distance) មានន័យថា យើងត្រូវនៅឆ្ងាយពីគ្នានៅក្នុងសង្គម ។ ក្រោយមកមានមនុស្សមួយចំនួនគិតថា ប្រសិនបើយើងឲ្យមនុស្សរស់នៅឆ្ងាយពីគ្នាក្នុងសង្គម ណែនាំឲ្យយើងបាក់បែកគ្នា យើងបោលទំនាក់ទំនងរវាងគ្នានឹងគ្នាយ៉ាងជាក់ស្តែង ។ ដូច្នេះគេបានដូរពីពាក្យ Social Distance ទៅជាពាក្យ Physical Distance មានន័យថាយើងអង្គុយឆ្ងាយពីគ្នាមួយម៉ែត្រកន្លះ ក៏ប៉ុន្តែយើងបន្តបង្កើតទំនាក់ទំនង ។ ខ្ញុំជឿថា ដើម្បីធ្វើជាសាក្សីនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់បន្ទាល់ សាក្សីនៃសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ គឺមានមធ្យោបាយតែមួយគឺមានទំនាក់ទំនងផ្ទាល់ ។

នៅថ្ងៃទី០១ ខែមិថុនា ខ្ញុំបានផ្សាយវីដេអូមួយដើម្បីជួយណែនាំឲ្យកូនកាយឫទ្ធិ និងមេកាយឫទ្ធិនៅក្នុងភូមិភាគភ្នំពេញ ឲ្យមានរបៀបរួមមួយដើម្បីប្រារព្ធទិវាកុមារអន្តរជាតិ ។ តាមព្រះសហគមន៍ មេកាយឫទ្ធិជាមួយកូនក្មេងបានរៀបចំកម្មវិធីតូចតាចតាមភូមិ នេះជាអ្វីដែលកូនក្មេងចងចាំ ។

ដោយសារជំងឺកូវីដ-១៩ ខ្ញុំបានភ្ជាប់នៅខេត្តនៅភូមិច្រើនណាស់ ពេលខ្ញុំនៅភូមិខ្ញុំជិះកង់រាល់ថ្ងៃ ។ ពេលជិះកង់ខ្ញុំបង្កើតទំនាក់ទំនងផ្សេង ពីពេលអង្គុយនៅក្នុងឡានមានម៉ាស៊ីនត្រជាក់ បិទបង្អួច ។

ពេលខ្ញុំនៅកំពតជិត២០ឆ្នាំមុន ខ្ញុំបានទៅផ្សារកំពតរាល់ថ្ងៃដើម្បីហូបបាយ កាត់អាវបូជាចារ្យ ខ្ញុំបានស្គាល់គេច្រើនណាស់ ។ សព្វថ្ងៃ យើងទៅផ្សារឡាក់គី ស៊ុបភើស្ទ័រ អ៊ីអន... តើយើងមានទំនាក់ទំនងស្គាល់គេទេ?

តើមានគម្រោងការព្រះសហគមន៍ប៉ុន្មានដែលត្រូវបង្កើតឡើង នៅពេលអង្គុយញ៉ាំកាហ្វេនៅក្នុងភូមិ ដោយចែករំលែកជាមួយប្រជាជននៅក្នុងភូមិអំពីបញ្ហា និងដំណោះ

ស្រាយ... **តើរបៀបដែលយើងបង្កើតទំនាក់ទំនងថ្មី នៅហាងកាហ្វេអាម៉ាហ្សូន ឬប្រោន... ដូចម្ដេចដែរ?**

យើងមើលហោរាចារ្យទាំងបីនាក់ គេបានធ្វើដំណើរដោយផ្ទាល់ដើម្បីថ្វាយបង្គំ គេមិនបានផ្ញើតង្វាយដល់ព្រះឱរសយេស៊ូតាមអ្នកបម្រើទេ ។

ពិតមែន យើងធ្លាប់និយាយថាមនុស្សយើងជាសត្វដែលមានទំនាក់ទំនងនៅក្នុងសង្គម ព្រះជាម្ចាស់បានចាប់កំណើតជាមនុស្ស ដូច្នេះសូមជឿខ្ញុំទំនាក់ទំនងលក្ខណៈសិប្បនិម្មិតមិនអាចជំនួសទំនាក់ទំនងផ្ទាល់បានទេ ។

ហេតុនេះហើយនៅឆ្នាំ២០២១នេះ សូមឲ្យយើងចំណាយពេលនៅតាមព្រះសហគមន៍នីមួយៗ នៅក្នុងសហគមន៍នីមួយៗ នៅក្នុងការិយាល័យនីមួយៗ នៅក្នុងស្ថាប័ននីមួយៗ ដើម្បីរួមគ្នាសម្រេចចិត្តយ៉ាងសកម្ម យើងធ្វើដូចម្ដេចដើម្បីផ្សព្វផ្សាយការប្រកាសដំណឹងល្អសាជាថ្មី ។

**តើយើងជាព្រះសហគមន៍កាតូលិកនៅក្នុងភូមិភាគភ្នំពេញ នៅក្នុងឆ្នាំ២០២១នេះនៅក្នុងបទពិសោធន៍នៃព្រំដែន និងបញ្ហានានាដែលយើងបានជួបប្លែកៗនៅក្នុងឆ្នាំ២០២០ ដោយសារកូវីដ-១៩ យើងអាចប្រកាសដំណឹងល្អនៅក្នុងរបៀបថ្មីដូចម្ដេច?**

**រីករាយឆ្នាំថ្មី ២០២១!**

**សូមព្រះជាម្ចាស់ប្រទានព្រះពរឱ្យបងប្អូន និងថែរក្សាបងប្អូននៅក្នុងសេចក្ដីសុខសាន្ដ និងអំណរសប្បាយរបស់ព្រះអង្គ!**

+ លោកអភិបាល អូលីវីយេ ជ្មិតហាស្លេរ

អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ

ប្រទេសកម្ពុជា

CARITAS CHRISTI URGET NOS

# EPIPHANY 2021

**"Because of the Good News... all Nations have the right to inheritance, to be whole in the body, to receive the blessing of the promise."**

Dear Brothers and Sisters,

This is the meaning of the Epiphany that we are celebrating today ... through the Magi from the East, God reveals to the World the birth of his Son.

God is the "Master of Communication" par excellence!

Magi, a Star, the Scriptures, King Herod, a dream ...

We are far from 4 / 5G, Internet and Facebook which make us "participate" in live at every times in all events around the world ... You tubers sometimes have millions of subscribers to whom they all speak the days without knowing them ...

Here, so few subscribers, a king who wants to kill ... a mother and a father with their newborn baby in a stable, in an obscure village of Judea ... and who is preparing to escape clandestinely to Egypt ...

And yet! 2000 years later we are still talking about it ... even in our cities in Asia, Christmas has invaded the place for weeks ... although there are only lighten trees and Santas Klaus left ...

For us, the restrictions of Covid 19 were the strongest during this year, on December 24-26 !!! A sign? Nevertheless, we were able to celebrate Christmas "as a family"… among ourselves… and thanks to our creativity, in many communities, there was Christmas for children, the elderly and the poor: the true Christmas of God made Man.

Today, as the restrictions are lifted, as we enter in the New Year with full of hopes: that of the vaccine, that of life resuming ... ***let us not forget our mission: to announce the Good News.***

You have received my wishes for 2021: blessing, living off the Word of God, affirming our Catholic identity, being firm in the faith, sharing the love of God in action...

But how can we be witnesses of the Good News in our society?

Everyone will have to sit down: the pastoral councils, the offices of the Vicariate, the priests, the religious communities, the Catholic NGOs: ***in the light of the Covid-19 in 2020, what have we learned from our weaknesses, from our strengths to fill our Mission: to announce the Good News?***

I will not answer it today, it will be our joint effort in 2021! But I would like to point out a point on this Epiphany morning: to announce the Good news, we have to communicate! But does communicating mean being on social media with thousands of virtual friends?

The Word became flesh on Christmas night… God comes to dwell not in the world in general or life in general… But in the village of Bethlehem, in Jesus with Mary and Joseph, in a small family.

The Word of God has incarnated and how to incarnate it today in this 21st century?

Paradoxically by being close to others socially and spiritually.

My whats app communication which was the most followed and appreciated were the specially offered masses, my bike pilgrimage offering for sufferings and all, my wishes for blessing and health: spiritual closeness.

Warning! Let's talk about physical distance, but not about social distance ... personal encounter, caring for others will always and again be the only way to witness the Gospel and the love of God ...

For Children's Day, I sent a short video, but isn't it the reality of the meeting of the Scout leaders with the children in the villages that has marked hearts? ...

During the Covid-19, I spent several months in the countryside on my bicycle every day ... so different than sitting in the car with the door closed?

How many relationships forged at the neighborhood market, what about modern Malls, Aeon, Superstor or Lucky?

How many dreams and projects shared at the local café, people met, problems shared and solved ... what about in the sanitized Amazon, Brown etc. cafes?

The three Magi came in person, they did not send their gifts by servants ...

Human being is a social animal ... God is embodied in our humanity ... and believe me, virtual communications will never replace personal relationships.

So for this year 2021… let us really take the time in each community, offices of the Vicariate to meditate together on our action and our "communication" to announce the Good News.

**HAPPY NEW YEAR 2021!**

**MAY GOD BLESS YOU AND KEEP YOU IN HIS PEACE AND JOY!**

+ Olivier Schmitthaeusler

Vicar Apostolic of Phnom Penh

CAMBODIA

# EPIPHANIE 2021

**“Voici ce secret: à cause de la Bonne Nouvelle, toutes les nations sont destinées à recevoir avec les Juifs les biens que Dieu réserve à son peuple, ils sont membres du même corps et bénéficient eux aussi de la promesse que Dieu a faite en Jésus-Christ.”**
**(Ephésiens 3, 2-6)**

Frères et Sœurs, c’est le sens de l’Epiphanie que nous célébrons aujourd’hui…par les Mages venus d’Orient, Dieu révèle au Monde la naissance de son Fils.

Dieu est le « Maitre de Communication » par excellence !

Des mages, une Etoile, les Ecritures, le roi Hérode, un songe…

Nous sommes loin de la 4/5G, d’Internet et de Facebook qui nous font « participer » en live à chaque instant à tous les évènements aux quatre coins du monde… Les You tubeurs ont parfois des millions d’abonnés auxquels ils parlent tous les jours sans les connaître…

Ici, si peu d’abonnés, un roi qui veut tuer… une mère et un père avec leur nouveau-né dans une étable, dans une obscure bourgade de Judée… et qui se prépare à fuir clandestinement en Egypte…

Et pourtant ! 2000 ans après on en parle encore…même dans nos villes d’Asie, Noël a envahi la place depuis des semaines…quoiqu’il ne reste plus que les sapins et les pères Noël…

Pour nous, les restrictions du Covid 19 ont été les plus fortes durant

cette année le 24-26 décembre !!! Un signe ? Néanmoins, nous avons pu célébrer Noel «  en famille »… entre nous… et grâce à notre créativité, dans de nombreuses communautés, il y a eu le Noël des enfants, des personnes âgées et pauvres : le vrai Noël de Dieu fait Homme.

Aujourd'hui, alors que les restrictions sont levées, que nous entrons dans l'année Nouvelle plein d'espoirs : celui du vaccin, celui de la vie qui reprend… n'oublions pas notre mission : annoncer la Bonne Nouvelle.

Vous avez reçu mes vœux pour 2021 : bénédiction,  vivre de la Parole de Dieu, affirmer son identité catholique, être ferme dans la foi, partager l'amour de Dieu en action…

Mais comment être témoins de la Bonne Nouvelle dans notre société ?

Chacun devra s'asseoir : les conseils pastoraux, les offices du Vicariat, les prêtres, les communautés religieuses, les ONGs catholiques : ***à la lumière du Covid-19 en 2020, qu'avons nous appris de nos faiblesses, de nos forces pour remplir notre Mission : annoncer la Bonne Nouvelle ?***

Je ne vais y répondre aujourd'hui, ce sera notre effort commun en 2021 !

Mais je voudrais pointer en ce matin de l'Epiphanie un point : **pour annoncer la Bonne nouvelle, il faut communiquer !** Mais communiquer est-ce être présents sur les réseaux sociaux avec des milliers d'amis virtuels ?

La Parole s'est faite chair en la nuit de Noël… Dieu vient habiter non pas le monde en général ou la vie en général… Mais le village de Bethléem en Jésus avec Marie et Joseph, dans une petite famille.

La Parole de Dieu s'est incarnée et comment s'incarner aujourd'hui en ce 21eme siècle… ***Paradoxalement en étant proches des autres socialement et spirituellement.***

Ma communication whats app qui a été la plus suivie et appréciée a été les messes offertes spécialement, mon pélé à vélo, mes vœux de bénédiction et de santé : la proximité spirituelle.

Attention ! Parlons de distance physique, mais pas de distance sociale… la rencontre personnelle, l'attention à l'autre sera toujours et encore le seul moyen d'être témoins de l'Evangile et de l'amour de Dieu…

Pour la journée des enfants, j'ai envoyé une petite vidéo mais n'est-ce pas la réalité de la rencontre des chefs scouts avec les enfants dans les villages qui a marque les cœurs ? …

Pendant le Covid-19, j'ai passé plusieurs mois à la campagne à vélo tous les jours… si diffèrent qu'assis dans la voiture porte fermées…

Combien de liens tissé au marché de quartier, qu'en est-il dans les Malls modernes, Aeon, Superstor ou Lucky ?

Combien de rêves et de projets partagés au café du coin, de personnes rencontrées, de problèmes partagés et résolus… qu'en est-il dans les cafés aseptisés Amazone, Brown etc.…?

Les rois mages sont venus en personne, ils n'ont pas envoyé leurs cadeaux par des serviteurs…

L'homme est un animal social… Dieu s'est incarné dans notre humanité… et croyez-moi, les communications virtuelles ne remplaceront jamais les relations personnelles.

Alors pour cette année 2021… prenons vraiment le temps dans chaque communauté, offices du Vicariat pour méditer ensemble à notre agir et notre « communication » pour annoncer la Bonne Nouvelle.

**BONNE ET HEUREUSE ANNEE 2021 !**

**QUE DIEU VOUS BENISSE ET VOUS GARDE DANS SA PAIX ET SA JOIE !**

+ Olivier Schmitthaeusler

Vicaire Apostolique de Phnom Penh

CAMBODGE



អបអរសាទរ
You Tube